ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួប ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន

******

នៅព្រឹកថ្ងៃទី **២៦ ខែតុលា ឆ្នាំ២០១៧** វេលាម៉ោង០៩:៤៥ នៅទីស្ដីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបឯកឧត្តម **Iwao HORII** អនុរដ្ឋមន្ត្រីការបរទេសរបស់ជប៉ុន ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការស្វាគមន៍ចំពោះដំណើរទស្សនកិច្ចរបស់ឯកឧត្តម **Iwao HORII** នៅកម្ពុជា ហើយក៏បានសម្ដែងនូវការអបអរសាទរយ៉ាងកក់ក្ដៅចំពោះជ័យជំនះដ៏ត្រចះត្រចង់របស់គណៈបក្សប្រជាធិបតេយ្យសេរីរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **Shinzo Abe** នៅក្នុងការបោះឆ្នោតជ្រើសតាំងសភានៅប្រទេសជប៉ុន ក្នុងសប្ដាហ៍កន្លងមកនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន គឺធ្វើឡើងនៅក្នុងឱកាសខួប៦០ឆ្នាំនៃដំណើរទស្សនកិច្ចនៅកម្ពុជាក្នុងឆ្នាំ១៩៥៧ របស់អតីតនាយករដ្ឋមន្ត្រីជប៉ុនឯកឧត្តម Nobusuke Kishi ហើយក៏ជាខួបលើកទី២៥ នៃការចូលរួមរបស់កងកំលាំងជប៉ុនលើកដំបូង ក្នុងការថែរក្សាសន្តិភាពនៅកម្ពុជា។ **ឯកឧត្តម** បានវាយតម្លៃថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តម **Iwao HORII** ក្នុងពេលនេះ នឹងជួយពង្រឹង-ពង្រីកបន្ថែមទៀតភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះជោគជ័យនៃដំណើរទស្សនកិច្ចការងារផ្លូវការរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ហើយនិងជំនួបទ្វេភាគីរវាងសម្ដេចតេជោ និងឯកឧត្តមនាយករដ្ឋមន្ត្រី **Shinzo Abe** នៅប្រទេសជប៉ុន ក្នុងខែសីហាកន្លងមកនេះ។ **ឯកឧត្តម** ក៏បានរំលឹកឡើងវិញពី ទស្សនកិច្ចនៅកម្ពុជាក្នុងខែឧសភាកន្លងមកនេះ របស់ឯកឧត្តម Nobuo Kishi អនុរដ្ឋមន្ត្រីការបរទេស និងរបស់ឯកឧត្តម Akitaka Saiki ទីប្រឹក្សារដ្ឋមន្ត្រីការបរទេសជប៉ុន ហើយនិងជំនួបពិភាក្សាការងារជាមួយឯកឧត្តមផ្ទាល់ លើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី តំបន់ និងអន្តរជាតិ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានឆ្លៀតឱកាសនេះ សម្ដែងនូវអំណរគុណ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ចំពោះការជួយឧបត្ថម្ភជាច្រើនរបស់ជប៉ុន ក្នុងដំណើរការសន្តិភាព ក៏ដូចជាក្នុងការស្ដារនិងអភិវឌ្ឍន៍ប្រទេសកម្ពុជា រហូតដល់ពេលបច្ចុប្បន្ន ។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានសម្តែងនូវការរីករាយពេញចិត្តចំពោះដំណើរទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅប្រទេសជប៉ុន ក្នុងខែសីហាកន្លងមក ហើយឯកឧត្តម ក៏បានជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី ថា គោលបំណងទស្សនកិច្ចនៅកម្ពុជារបស់ឯកឧត្តមនៅពេលនេះ គឺដើម្បីបង្ហាញអោយឃើញថាជប៉ុនចាត់ទុកកម្ពុជាគឺជាមិត្តភ័ក្រពិសេស ហើយជំហរនេះនឹងពុំមានការប្រែប្រួលឡើយ។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** ក៏បានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ថា ជប៉ុននឹងបើកស្ថានកុងស៊ុលរបស់ជប៉ុនប្រចាំនៅសៀមរាប នៅក្នុងខែមករា ឆ្នាំ២០១៨ ខាងមុខនេះ ហើយនិងបន្តយកចិត្តទុកដាក់ពង្រឹងបន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្ររវាងជប៉ុន-កម្ពុជា។ **ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ ពិសេសគឺការផ្លាស់ប្តូរការគាំទ្រគ្នាទៅវិញទៅមក នៅលើវេទិកាតំបន់ និងវេទិកាអន្តរជាតិជាច្រើន ។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** ក៏បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៅកម្ពុជាបច្ចុប្បន្ន និងបានអះអាងជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** ថា រដ្ឋាភិបាលជប៉ុន នឹងបន្តផ្តល់ជំនួយឧបត្ថម្ភដល់កម្ពុជា ក្រោមកម្មវិធីកិច្ចសហប្រតិបត្តិការរវាងជប៉ុននិងកម្ពុជា។ **ឯកឧត្តម** បានជម្រាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការគិតគូររបស់រដ្ឋាភិបាលជប៉ុន ក្នុងការជួយដល់កម្ពុជាលើការកែទម្រង់គ្រប់វិស័យ ពិសេសការបង្កើនសមត្ថភាពរបស់កំពង់ផែក្រុងព្រះសីហនុ ដើម្បីឆ្លើយតបនឹងការទាក់ទាញក្រុមហ៊ុនរបស់ជប៉ុនឲ្យមកធ្វើវិនិយោគទុននៅកម្ពុជា ហើយនិងការដោះស្រាយបញ្ហាចរាចរណ៍នៅទីក្រុងភ្នំពេញ ដែលឯកឧត្តម បានគូសបញ្ជាក់ថា បច្ចុប្បន្ន ជប៉ុនបានចាប់ផ្តើមធ្វើការសិក្សាអំពីគម្រោងបង្កើតរថភ្លើងធុនស្រាលលើអាកាសនៅទីក្រុងភ្នំពេញ ដើម្បីជួយដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានសម្តែងនូវការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការលើវិស័យការពារប្រទេសរវាងប្រទេសទាំងពីរ ពិសេសគឺតាមរយៈការអញ្ជើញទៅបំពេញទស្សនកិច្ចរបស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិនៅប្រទេសជប៉ុនក្នុងខែកញ្ញាកន្លងមកនេះ។ **ឯកឧត្តម** ក៏បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ពិសេសគឺយុវជននៃប្រទេសទាំងពីរ។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** ក៏បានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ថា នៅក្នុងឆ្នាំ ២០១៨ ខាងមុខនេះ គឺជាខួបទី៦៥នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយជប៉ុនមានបំណងពង្រឹង និងពង្រីកបន្ថែមទៀតនូវទំនាក់មិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ ចំពោះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលជប៉ុន ក្នុងការលើកស្ទួយទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ។ ឯកឧត្តម ក៏បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុនដែលបានផ្តល់នូវការគាំទ្រដ៏សកម្មចំពោះកម្ពុជា ក្នុងក្របខណ្ឌទ្វេភាគី តំបន់ និងលើវេទិការអន្តរជាតិ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ថា ការរីកចម្រើនរបស់កម្ពុជា រហូតដល់ពេលនេះ គឺមិនអាចកាត់ផ្តាច់បានពីការជួយជំនួយឧបត្ថម្ភជាច្រើនរបស់ជប៉ុន ហើយឯកឧត្តមទេសរដ្ឋមន្ត្រី បានសម្តែងនូវអំណរគុណចំពោះការអះអាងរបស់អនុរដ្ឋមន្ត្រីការបរទេសជប៉ុនថា ជប៉ុននឹងបន្តផ្តល់ជំនួយដល់កម្ពុជា និងថា ការគាំទ្ររបស់ជប៉ុនចំពោះកម្ពុជានឹងពុំមានការផ្លាស់ប្តូរឡើយ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានទទួលយកកម្មសិក្សាការីកម្ពុជារាប់ពាន់នាក់ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលជំនាញនៅប្រទេសជប៉ុន ដែលឯក**ឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា កម្មវិធីនេះគឺបានផ្តល់នូវការចំណេញពីរយ៉ាងដល់កម្មសិក្សាការីរបស់កម្ពុជា គឺ ម្យ៉ាងទទួលបានការបណ្តុះបណ្តាលជំនាញ ទទឹមនឹងនោះក៏ទទួលបានប្រាក់បៀវត្សទៀតផង ហើយក្រោយពេលវិលត្រលប់មកវិញ កម្មសិក្សាការីទាំងអស់នោះអាចនាំយកនូវបទពិសោធន៍ និងជំនាញរបស់ខ្លួន មកបំរើដល់ការកសាងប្រទេសកម្ពុជា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវអំណរគុណក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាចំពោះការផ្តល់ជំនួយឥតសំណង ក៏ដូចជាការផ្តល់នូវឥណទានសម្បទានចំពោះកម្ពុជា ក្នុងរយៈកាលកន្លងមក។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការកើនឡើងយ៉ាងខ្លាំងរបស់វិនិយោគទុនជប៉ុននៅកម្ពុជា ដែលនៅក្នុងឆ្នាំ២០១៦កន្លងមក បានកើនឡើងដល់ចំនួនជាង**៨០០លានដុល្លារ**។

លើវិស័យទេសចរណ៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី** និង**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន** បានសម្តែងការវាយតម្លៃខ្ពស់ចំពោះការកើនឡើងទំនាក់ទំនងផ្នែកទេសចរណ៍ ពិសេសចាប់តាំងពីការបង្កើតឡើងនូវជើងហោះហើរត្រង់រវាងប្រទេសទាំងពីរ កាលពីថ្ងៃទី ០១ ខែ **កញ្ញា ឆ្នាំ២០១៦** កន្លងមកនេះ។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** ក៏បានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការវាយតម្លៃខ្ពស់របស់ជប៉ុន ចំពោះការចូលរួមរបស់កងកម្លាំងមួកខៀវរបស់កម្ពុជាក្នុងបេសកកម្មថែរក្សាសន្តិភាពពិភពលោក ក្នុងក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងមោទនភាពរបស់កម្ពុជាក្នុងការបញ្ជូនកងកម្លាំងរបស់ខ្លួនចំនួនជាង៤៧០០នាក់ក្នុងរយៈពេល១១ឆ្នាំកន្លងមកនេះ ចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងបានថ្លែងអំណរគុណចំពោះជប៉ុន ដែលកន្លងមកបានផ្តល់នូវការជួយបណ្តុះបណ្តាលដល់កងកម្លាំងមួកខៀវកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះការជួយឧបត្ថម្ភរបស់ជប៉ុនដល់ការរៀបចំការបោះឆ្នោត និងការបញ្ជូនអ្នកសង្កេតការណ៍ជប៉ុនចូលរួមក្នុងការបោះឆ្នោតឃុំ-សង្កាត់កន្លងមក។ **ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានជម្រាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** ថា ជប៉ុននឹងបន្តជួយដល់កម្ពុជាក្នុងការបោះឆ្នោតទូទៅឆ្នាំ២០១៨ខាងមុខនេះទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានឆ្លៀតឱកាសនេះ ធ្វើការពន្យល់បកស្រាយអំពីសភាពការណ៍ដែលកើតមាននៅកម្ពុជា បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ពិសេសគឺធ្វើការបំភ្លឺទាត់ចោលចំពោះការចោទប្រកាន់ដោយអយុត្តិធម៌របស់មជ្ឈដ្ឋានមួយចំនួនចំពោះរាជរដ្ឋាភិបាលកម្ពុជាលើករណីកាសែត Cambodia Daily ការបិទអង្គការNDI និងករណីការឃុបឃិតក្បត់ជាតិរបស់ប្រធានគណបក្សប្រឆាំងជាមួយមហាអំណាចបរទេស សំដៅធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានសំដែងអំណរគុណចំពោះការពន្យល់បំភ្លឺរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** ហើយបានគូសបញ្ជាក់ថា ជប៉ុនគោរពជំហររបស់កម្ពុជា និងថា ការគាំទ្ររបស់ជប៉ុនចំពោះកម្ពុជា នឹងពុំមានការប្រែប្រួលឡើយ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និង**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន** ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាផងដែរ អំពីសភាពការណ៍តំបន់ និងសភាពការណ៍អន្តរជាតិមួយចំនួន ពិសេសគឺ សភាពការណ៍នៅឧបទ្វីបកូរ៉េ និងបញ្ហានៅសមុទ្រចិនខាងត្បូង។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១៧